# ឯកឧត្តម ទេសរដ្ឋមន្ត្រី ជួបនាយកអង្គការ(GGGI) ដែលមានមូលដ្ឋាននៅប្រទេសកូរ៉េ



នៅព្រឹកថ្ងៃទី០៤ ខែ សីហា ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបលោកបណ្ឌិត **Imran Habib Ahmad** នាយកប្រចាំអាស៊ីបូព៌ា និង ប៉ាស៊ីហ្វិក នៃអង្គការវិទ្យាស្ថានអភិវឌ្ឍន៍បៃតងពិភពលោក (GGGI) និងសហការី ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។

ក្នុងជំនួបពិភាក្សានោះ លោក **Imran Habib Ahmad** បានជម្រាបជូនពីសកម្មភាពការងាររបស់អង្គការវិទ្យាស្ថាន GGGI ក្នុងការអនុវត្តគម្រោងការនានាទាក់ទងនិងការរួមចំណែកអភិវឌ្ឍន៍ទីក្រុងបៃតង នៅក្នុងតំបន់ ។ ក្នុងជំនួបនាថ្ងៃនេះ ប្រតិភូរបស់លោក មានបំណងចង់ស្វែងយល់ និងសហការការងារ ដោយស្នើឱ្យភាគីកម្ពុជា បង្កើតនូវចំណុចទំនាក់ទំនង សម្រាប់សហការធ្វើការងារស្រួល ហើយក៏ចង់ដឹងពីតម្រូវការរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មផងដែរ ។



លោកនាយក អង្គការ GGGI ក៏បានជម្រាបជូនថាៈ នៅថ្ងៃទី០៦-០៧ ខែ សីហា ខាងមុខនេះ អង្គការវិទ្យាស្ថាន របស់លោក សហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចិរភាព នឹងរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "កម្មវិធីអភិវឌ្ឍន៍ទីប្រជុំជនក្រុងបៃតងនៅកម្ពុជា" នៅខេត្តកែប ហើយបានស្នើអញ្ជើញតំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្មចូលរួមជាកិត្តិយសផងដែរ ។




ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងចាត់ទុកសកម្មភាពការងាររបស់ អង្គការវិទ្យាស្ថាន GGGI នៅកម្ពុជា ជាដៃគូសហការដ៏ល្អ ពីព្រោះរាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍន៍បៃតងនេះតាំងពីឆ្នាំ២០០៤ ដោយផ្តោតលើការងារចាំបាច់មួយចំនួន ដូចជាៈឧស្សាហកម្មបៃតង ប្រសិទ្ធិភាពថាមពល ក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម និងការផ្ទេរបច្ចេកវិទ្យាអំណោយផលដល់បរិស្ថានជាដើម។



ស្ថិតនៅក្នុងឱកាសនោះ ឯកឧត្តម បានស្នើឱ្យ អង្គការ GGGI ពិនិត្យលទ្ធភាពជួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើវិស័យទឹកស្អាត ជាពិសេសការពិនិត្យមើលការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋនៅទីជនបទ ដែលយើងមិនដឹងប្រាកដថាមានសុវត្ថិភាពដល់កំរិតណា? និងជួយផ្នែកអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម និងអភិវឌ្ឍន៍ឧស្សាហកម្មកាន់តែបៃតងជាដើម ។ ចំពោះចំណុចទំនាក់ទំនង ក្នុងក្រសួង ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានប្រគល់ភារកិច្ច ឱ្យឯកឧត្តមបណ្ឌិត **ទឹង ស៊ុនី** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារនេះ ហើយ ឯកឧត្តម បានស្នើឱ្យមានការគិតគូរៀបចំសិក្ខាសាលាដោយអញ្ជើញឧស្សាហករ សិប្បករ ក៏ដូចជាសហគ្រិន នៅក្នុងស្រុក ចូលរួមស្វែងយល់នូវបទឧទ្ទេសនាម ពីតំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងតំណាងអង្គការ GGGI ពីអត្ថប្រយោជន៍នានា នៃការអភិវឌ្ឍន៍ទីក្រុងបៃតង ក៏ដូចជាឧស្សាហកម្មកាន់តែបៃតង នៅកម្ពុជា ។